ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បណ្ដាញអនុវត្តបច្ចេកវិទ្យា

# ការចិញ្ចឹម និងគ្រប់គ្រងទានៅជនបទ




រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី

**រៀបរៀងដោយៈ បណ្ឌិត ខៀវ បូរិន**
**មជ្ឈមណ្ឌលអភិវឌ្ឍន៍ការចិញ្ចឹមសត្វ និងកសិកម្ម “សែលអាគ្រីត”**
ទូរស័ព្ទៈ ០២៣ ២២៣៦៤០
អ៊ីម៉ែលៈ celagrid@celagrid.org

**កាលបរិច្ឆេទៈ ខែ កក្កដា ឆ្នាំ ២០០៦**

© រក្សាសិទ្ធិគ្រប់យ៉ាងៈ គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

**បុព្វកថា**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ន និង ប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជាបានខិតខំយ៉ាងពេញទំហឹង ដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និង បានចងក្រងជាបទដ្ឋានអនុវត្តបច្ចេក វិទ្យានេះឡើង ។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះបានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹង ត្រូវបានឆ្លងការពិនិត្យពិគ្រោះយោបល់ និង ឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាព មកពីនាយកដ្ឋានជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗ ទៀត ។ ឯក សារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពីព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និង ផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយក ទៅប្រើប្រាស់ ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាម គ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង ផលិតករដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាម លក្ខខ័ណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្ម កសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និង បង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់ បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជា ឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាលភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម ។

**រដ្ឋមន្ត្រី**

## អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ (បទដ្ឋានអនុវត្តបច្ចេកវិទ្យា)។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យា ដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ ។បអបផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់ឱ្យមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និង ខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការ ក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀតដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៏កសិកម្មនៅតាមមូលដ្ឋានប្រើប្រាស់ ។

បអប មានលក្ខណៈដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករតាមរយៈប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័តិមានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម(FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗរបស់កសិករ ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប មាននៅតាមស្ថាប័ននានាដូចខាងក្រោម:

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មកអនុម័តនិងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន ។

## ១. សេចក្ដីអធិប្បាយ

**សេចក្ដីសង្ខេប**

**បញ្ហា** អាត្រារស់ទាបពេលទានៅតូចៗ និងផលិតកម្មស៊ុតទាប

**គោលបំណង** ផលិតកូនទាមានសុខភាពល្អសម្រាប់ចិញ្ចឹមរហូតដល់ដំណាក់កាលផលិតស៊ុត និងការពារពី ជំងឺផ្សេងៗ ។

**វិធីសាស្ត្រ**

១. ជ្រើសរើសកូនទាដែលមានសុខភាពល្អ

២. បង្កាត់ទាសម្រាប់ផលិតសាច់ និងស៊ុតបានខ្ពស់

៣. ផ្ដល់ការថែទាំចាប់ពីដំណាក់កាលកូនទារហូតដល់ទាពង

៤. រៀបចំចំណីបានល្អ

៥. ធ្វើការគ្រប់គ្រងបានប្រសើរ តាមដំណាក់កាលនៃអាយុរបស់ទា

**គោលបំណង និងផលប្រយោជន៍**

- ផ្ដល់ដល់ភ្នាក់ងារផ្សព្វផ្សាយនូវការណែនាំបច្ចេកទេស និងផ្សព្វផ្សាយសាមញ្ញ និងសមរម្យដើម្បីឱ្យផ្ទេរព័ត៌មាន-សារដល់កសិករសម្រាប់កែលំអផលិតកម្មមាន់ក្នុងស្រុកនៅជនបទ។
- ផ្ដល់ដល់ភ្នាក់ងារផ្សព្វផ្សាយនូវជម្រើសបច្ចេកទេស អាស្រ័យទៅតាមលក្ខខណ្ឌ និងធនធានដែលមាននៅតាមតំបន់និមួយៗ និង។
- ភ្នាក់ងារផ្សព្វផ្សាយអាចប្រើប្រាស់ បអប 'TIP'នេះដើម្បីបង្កើនចំណូលសេដ្ឋកិច្ចគ្រួសារកសិករតាមរយៈការកែលំអចំណី ការគ្រប់គ្រង និងថែទាំទា ។

**លក្ខណៈវិនិច្ឆ័យបច្ចេកទេសសមស្រប:**

ខាងក្រោមនេះ ជាលក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តន៍ បអប 'TIP'នេះ ដើម្បីសំរេចជោគជ័យលើទិសដៅលើកឡើងលើ។

**យែនឌ័រ:**

- ករណី ហ្វូងទា ៣០-៣៥ ក្បាល អាចទទួលខុសត្រូវក្នុងការថែទាំ តែនៅពេលដែលហ្វូងទាមានចំនួន ១០០-១៥០ក្បាល បុរសអាចចូលរួមក្នុងការសាងសង់ទ្រុង ។